**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

គណៈកម្មាធិការលទ្ធកម្ម

លេខ : .០១..../២២ គល

# សេចក្ដីជូនដំណឹង

## ស្ដីពី

## ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់ថ្នាំចាក់ការពារ និងព្យាបាលសត្វ ប្រចាំឆមាសទី១ ឆ្នាំ២០២២ របស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុន (គិតទាំងសហគ្រាស ឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកផ្គត់ផ្គង់ថ្នាំចាក់ការពារ និងព្យាបាលសត្វ ប្រចាំឆមាសទី១ ឆ្នាំ២០២២ របស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានអាសយដ្ឋានលេខ២០០ មហាវិថីព្រះនរោត្ដម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី..០១........ខែ..មេសា..ឆ្នាំ២០២២ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០១២ ៩១៦ ៩២៦ , ០១៦ ៦១ ៦៦ ៨២ )។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ យ៉ាងយូរបំផុតត្រឹមថ្ងៃទី.០៣.....ខែ.ឧសភា.ឆ្នាំ២០២២ វេលាម៉ោង ..០៩:០០..............។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមអាសយដ្ឋានខាងលើ វេលាម៉ោង.០៩:០០.....ថ្ងៃទី ០៣..... ខែ.ឧសភា. ឆ្នាំ២០២២។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃ.ព្រហស្បតិ៍ ១កើត..ខែ..ផល្គុន....ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ..០៣..... ខែ.មីនា...ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម**

**វេង សាខុន**

**ចម្លងជូន៖**

- -អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- -អង្គភាពប្រឆាំងអំពើពុករលួយ
- -ឯកសារ កាលប្បវត្តិ

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
Nº 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone : (023) 726 128 / 726 129, Fax: (855) 23-217 320